# ចែករំលែកចំណេះដឹងនៃបទពិសោធន៍
# SHARE EXPERIENCE KNOWLEDGE

**បទពិសោធន៍នៃជំនាញ**
**(Skill Experience)**

ប្រធានបទសម្រាប់ចែករំលែក (Subject to be shared) : **ការស្វែងរក និងការដាក់ពាក្យសុំធ្វើការ**

កាលបរិច្ឆេទនៃការចែករំលែក (Date of this sharing) : ២៤ មិនា ២០១២

ចែករំលែកបទពិសោធន៍ដោយ (Experience shared by) : លោក សៀង ប៊ូហឿង

## ១. និយមន័យ (Definition)

ការស្វែងរក និងការដាក់ពាក្យសុំធ្វើការ គឺសំដៅទៅលើការស្វះស្វែងក្នុងការទទួលបានព័ត៌មានការងារ ការបំពេញបែបបទដាក់ពាក្យសុំធ្វើការ ការត្រៀមលក្ខណៈ និងការទំនាក់ទំនងដើម្បីទទួលបានជោគជ័យក្នុងការស្វែងរកការងារ ក៏ដូចជាការទទួលបានការងារធ្វើ ។

## ២. ដំណើរការប្រតិបត្តិ (Procedure)

ដំណើរការនៃការស្វែងរក និងការដាក់ពាក្យសុំធ្វើការ មានដូចតទៅ៖

ក. សេចក្តីជូនដំណឹង ឬព័ត៌មានអំពីការងារអាចរកឃើញនៅតាម សារព័ត៌មាន ឬកាសែតមួយចំនួន (កាសែតកោះសន្តិភាព កាសែតរស្មីកម្ពុជា កាសែតខែមបូឌាដេលី ...។ល។) គេហទំព័រមួយចំនួន (www.bongthom.com, www.camhr.com, www.pelprek.com, ...។ល។) ការបិតប្រកាសតាមវិទ្យាស្ថាន ឬសាកលវិទ្យាល័យមួយចំនួន ការបិតប្រកាសតាមអង្គភាពមួយចំនួន ការជូនដំណឹងអំពីតម្រូវការការងារតាមទូរទស្សន៍ ឬវិទ្យុ និងការទទួលបានព័ត៌មានពីមិត្តភ័ក្ត ឬអ្នកដទៃទៀតដែលស្គាល់អ្នក និងបានដឹងព័ត៌មានការងារ ។

ខ. ការបំពេញបែបបទដាក់ពាក្យសុំធ្វើការ គឺត្រូវមានលិខិតអម (Cover Letter) ប្រវត្តិរូបសង្ខេប (CV) និងឯកសារភ្ជាប់ ឬឯកសារពាក់ព័ន្ធ មានដូចជាលិខិតបញ្ជាក់ការងារមុនៗ លិខិតបញ្ជាក់ការសិក្សា និងសញ្ញាបត្រជាដើម។ (ទម្រង់បែបបទរបស់អង្គភាព អាចនឹងតម្រូវអោយបំពេញ ប្រសិនបើមានការទាមទារពីអង្គភាព។)

គ. ការដាក់ពាក្យសុំធ្វើការ អាចនៅនឹងកន្លែងនៃអង្គភាព តាមប្រព័ន្ធអ៊ីធឺណេត ឬតាមភ្នាក់ងារ អាស្រ័យទៅលើការអាចទទួលយកបាន របស់អង្គភាពដូចមានចែងក្នុងសេចក្តីជូនដំណឹង ហើយត្រូវដាក់អោយបានទាន់ពេលវេលាតាមការកំណត់របស់អង្គភាព។

ឃ. ការត្រៀមលក្ខណៈ គឺថាអ្នកត្រូវដឹងថាការងារដែលអ្នកដាក់ពាក្យសុំនោះ ជាការងារអ្វី និងមានការទាមទារអ្វីខ្លះ ហើយត្រូវសិក្សាពីប្រវត្ត និងលក្ខណៈទូទៅរបស់អង្គភាពតាមរយៈគេហទំព័រ ឬតាមវិធីសាស្ត្រផ្សេងៗទៀត ប្រសិនបើអាច ពីព្រោះថាការសម្ភាសន៍អាចនឹងសួរអំពីអង្គភាព មុននឹងសួរអំពីសំណួរផ្សេងៗដើម្បីដឹងអំពីសមត្ថភាពរបស់អ្នក។ ម្យ៉ាងវិញទៀត អ្នកត្រូវស្គាល់ខ្លួនឯងអោយបានច្បាស់ មានន័យថាអ្នកត្រូវមានភាពស្ទាត់ជំនាញទៅនឹងការឆ្លើយ ឬការរៀបរាប់អំពីប្រវត្តិនៃការសិក្សាអប់រំ និងបទពិសោធន៍ នៃការងាររបស់អ្នក ។

ង. ពេលសម្ភាសន៍ អ្នកត្រូវមានភាពអត់ធ្មត់កម្រិតខ្ពស់បំផុត ទោះក្នុងលក្ខខណ្ឌណាក៏ដោយ ហើយត្រូវរៀបចំវិជ្ជាសម្បត្តិ និងចរិយាសម្បត្តិរបស់អ្នក អោយបានសមរម្យទៅតាមការងារ និងតាមតំបន់ ។ (ក្រោយពេលសម្ភាសន៍ អ្នកក៏អាចធ្វើការទំនាក់ទំនងដើម្បីទទួលបានព័ត៌មានអំពីលទ្ធផល ក៏ដូចជាការបង្ហាញអំពីចំណាប់អារម្មណ៍ខ្ពស់របស់អ្នកចំពោះការងារនោះ ។)

**៣. សេចក្តីសន្និដ្ឋាន (Conclusion)**

ការប្រតិបត្តិដូចបានរៀបរាប់ខាង គឺពិតជាមានសារៈសំខាន់ណាស់ សម្រាប់អ្នកដែលកំពុងស្វែងរកការងារធ្វើ ។ ទោះបីជាយ៉ាងណាក៏ដោយ ការរៀបរាប់ខាងលើ គឺគ្រាន់តែជាការរៀបរាប់ដោយសង្ខេបតែប៉ុណ្ណោះ ។